# ព្រះអម្ចាស់ ទ្រង់ជាអ្នក ព្យាបាលរបស់ខ្ញុំ

ព្រលឹងខ្ញុំអើយ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ហើយកុំឲ្យភ្លេចបណ្តាព្រះគុណណាមួយរបស់ទ្រង់ឡើយ ដែលទ្រង់អត់ទោសចំពោះអស់ទាំងការទុច្ចរិតរបស់ខ្ញុំ ទ្រង់ប្រោសជំងឺទាំងប៉ុន្មានរបស់ខ្ញុំឲ្យជា ក៏ជួយជីវិតខ្ញុំឲ្យរួចពីរណ្តៅហើយយកសេចក្តីសប្បុរស និងសេចក្តីមេត្តាករុណាបំពាក់ជាមកុដឲ្យខ្ញុំវិញ។ (១)

ព្រះអម្ចាស់អើយ ខ្ញុំរង់ចាំទ្រង់ ដ្បិតទ្រង់ឱ្យខ្ញុំមានកំឡាំងចំរើនជានិច្ច ខ្ញុំនឹងហើរឡើងទៅលើ ដោយស្លាបដូចជាឥន្ទ្រី ខ្ញុំនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ។ (២)

ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់ខ្ញុំ ហើយបានទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់ខ្ញុំពិត ប៉ុន្តែខ្ញុំបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរង វេទនា។ តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់ខ្ញុំ ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់ខ្ញុំ ឯការវាយផ្ចាលដែលនាំឲ្យខ្ញុំបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយខ្ញុំត្រូវបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់។ (៣)

ខ្ញុំបានផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយ ព្រមទាំងបញ្ហារបស់ខ្ញុំទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងខ្ញុំ។ (៤)

ព្រះអម្ចាស់អើយ ទ្រង់គឺជាព្រះដែលប្រោសខ្ញុំឲ្យជាសះស្បើយ។(៥)

(១) ទំនុកតម្កើង ១០៣: ២-៤
(២) អេសាយ ៤០: ៣១
(៣) អេសាយ ៥៣: ៤-៥
(៤) ១ពេត្រុស ៥: ៧
(៥) និក្ខមន៍ ១៥: ២៦

**ទំនុកតម្កើង ១០៣: ២-៤** ព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ហើយកុំឲ្យភ្លេចបណ្តាព្រះគុណណាមួយរបស់ទ្រង់ឡើយ ដែលទ្រង់អត់ទោសចំពោះអស់ទាំងការទុច្ចរិតរបស់ឯង ទ្រង់ប្រោសជំងឺទាំងប៉ុន្មានរបស់ឯងឲ្យជា ក៏ជួយជីវិតឯងឲ្យរួចពីរណ្តៅ ហើយយកសេចក្តីសប្បុរស និងសេចក្តីមេត្តាករុណាបំពាក់ជាមកុដឲ្យឯងវិញ។

**អេសាយ ៤០: ៣១** តែអស់អ្នកណាដែលសង្ឃឹមដល់ព្រះយេហូវ៉ាវិញ នោះនឹងមានកំឡាំងចំរើនជានិច្ច គេនឹងហើរឡើងទៅលើ ដោយស្លាប ដូចជាឥន្ទ្រី គេនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ។

**អេសាយ ៥៣: ៤-៥** ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់យើង ហើយបានទទួលផ្ទុកអស់ទាំងសេចក្តីទុក្ខព្រួយរបស់យើងពិត ប៉ុន្តែយើងរាល់គ្នាបានរាប់ទ្រង់ទុកជាអ្នកមានទោសវិញ គឺជាអ្នកដែលព្រះបានវាយ ជាអ្នកដែលរងវេទនា ៥ តែទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់ ។

**១ពេត្រុស ៥ : ៧** ហើយចូរផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា។

**និក្ខមនំ ១៥: ២៦** ទ្រង់មានព្រះបន្ទូលថា បើឯងរាល់គ្នាប្រុងនឹងស្តាប់តាមព្រះយេហូវ៉ា ជាព្រះនៃឯង ហើយធ្វើការត្រឹមត្រូវនៅព្រះនេត្រនៃទ្រង់ ព្រមទាំងផ្ទៀងត្រចៀកស្តាប់តាមបញ្ញត្តទ្រង់ ហើយកាន់តាមច្បាប់ទ្រង់ទាំងប៉ុន្មាន នោះអញនឹងមិនធ្វើឲ្យឯងរាល់គ្នាកើតមានជំងឺរោគាណាមួយ ដូចជាអញបានធ្វើឲ្យកើតឡើងដល់ពួកសាសន៍អេស៊ីព្ទនោះឡើយ ដ្បិតអញនេះជាយេហូវ៉ា គឺជាព្រះដែលប្រោសឯងរាល់គ្នាឲ្យជា។

**បកប្រែដោយ: ONE -2- ONE CAMBODIA**
**អាស័យដ្ឋាន: # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**
**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**
**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**
www.One-2-One world.org
www.derekprince.co.nz PC09